00702464

**Declassified to Public**
**12 June 2020**

លេខ / No: D 7/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Siegfried BLUNK**

កាលបរិច្ឆេទ ៖ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

---

**ដីកាសម្រេចស្តីអំពីសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំផ្ទេរឯកសារ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីចេញពីសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៤**

---

<u>សហព្រះរាជអាជ្ញា</u>
លោកស្រី ជា លាង
លោក Andrew CAYLEY

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 06 / 2011
ម៉ោង (Time/Heure) : 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D7/1

យើង **យូ ប៊ុនឡេង** និង Siegfried BLUNK **(ស៊ីគហ្វ្រីដ ប្លុង)** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញវិធាន ១៣(៣) វិធាន ១៣(៥) វិធាន ២១ វិធាន ៦៦ វិធាន ៧១(១) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. (“វិធានផ្ទៃក្នុង”)

បានឃើញការស៊ើបសួរដែលកំពុងដំណើរការ ដោយអនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

បានឃើញសំណើសុំដែលដាក់ក្នុងនាមសហព្រះរាជអាជ្ញាអន្តរជាតិតែឯកឯង និងមានចម្លងជូនសហព្រះរាជអាជ្ញាជាតិ

ដោយហេតុថា ដោយអនុលោមតាមវិធាន ១៣ ការិយាល័យសហព្រះរាជអាជ្ញាមានតែមួយប៉ុណ្ណោះ ហើយជាគោលការណ៍សហព្រះរាជអាជ្ញាទាំងពីរត្រូវបំពេញសកម្មភាពរួមគ្នានៅក្នុងដំណើរការនីតិវិធី ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី នៅក្នុងករណីមួយចំនួន សហព្រះរាជអាជ្ញាមួយរូបអាចនឹងបំពេញសកម្មភាពតែម្នាក់ឯងបាន បន្ទាប់ពីទទួលបានការផ្ទេរអំណាចតាមរយៈសេចក្តីសម្រេចរួមមួយដោយអនុលោមតាមបញ្ញត្តិនៃវិធាន ១៣(៣) ឬបន្ទាប់ពីសហព្រះរាជអាជ្ញាកត់ត្រាកំណត់ហេតុអំពីការខ្វែងយោបល់គ្នា ស្របតាមបញ្ញត្តិនៃវិធាន ៧១(១) នៃវិធានផ្ទៃក្នុង ។

ដោយហេតុថា ដោយអនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលនៃការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព សហចៅក្រមស៊ើបអង្កេតចាំបាច់ធានាអំពីការគោរពបញ្ញត្តិច្បាប់ដែលមានចែងក្នុងវិធាន ១៣(៣) និងវិធាន ៧១(១) នៃវិធានផ្ទៃក្នុង ។

00702466

០០៤/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D7/1

**អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត**

**សម្រេច** បង្គាប់សហព្រះរាជអាជ្ញាឲ្យធ្វើការបង្ហាញក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការថា មុននឹងមានការដាក់សំណើសុំឲ្យមានការផ្ទេរឯកសារ និងភស្តុតាងផ្សេងទៀតចូលក្នុងសំណុំរឿង ០០៤ តើសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសម្រេចផ្ទេរអំណាចដោយអនុលោមតាមវិធាន ១៣(៣) នៃវិធានផ្ទៃក្នុង ឬបានកត់ត្រាកំណត់ហេតុនៃការខ្វែងយោបល់គ្នា ស្របតាមបញ្ញត្តិនៃវិធាន ៧១(១) ដែរ ឬយ៉ាងណា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១

សហចៅក្រមស៊ើបអង្កេត
Co-Investigating Judges
Co-juges d'instruction

Dr. Siegfried BLUNK

យូ ប៊ុនឡេង